00939313

E138/1/10/1/5/8/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 07 / 2013
ម៉ោង (Time/Heure): 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

កាលបរិច្ឆេទ: ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៣
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# ដីកាបង្គាប់ស្តីពីវិធានការដែលត្រូវអនុវត្តចំពោះជនជាប់ចោទ អៀង ធីរិទ្ធ

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
អៀង ធីរិទ្ធ

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីការពារក្តី**
ផាត់ ពៅស៊ាង
Diana ELLIS

## ក. សេចក្ដីផ្ដើម

១. អង្គជំនុំជម្រះសាលាដំបូងសូមរំឮកឡើងវិញនូវសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ស្ដីពី "សំណើរបស់អង្គជំនុំជម្រះសាលាដំបូង និងមេធាវីការពារក្ដី អៀង ធីរិទ្ធ សុំការណែនាំ និងការបញ្ជាក់បំភ្លឺលក្ខខណ្ឌនៃការដោះលែង អៀង ធីរិទ្ធ" (E138/1/10/1/5/8/2 ឯកសារ) ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ ("សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ស្ដីពីការត្រួតពិនិត្យ និងការបញ្ជាក់បំភ្លឺលក្ខខណ្ឌនៃការដោះលែង")។

២. ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងសូមរំឮកឡើងវិញផងដែរអំពីអនុស្សរណៈរបស់ខ្លួនដែលមានចំណងជើងថា "សំណើរបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ សុំការបញ្ជាក់បំភ្លឺអំពីការអនុវត្តសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ" (ឯកសារ E138/1/10/1/5/8/3) ដែលនៅក្នុងនោះ អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីពាក់ព័ន្ធអំពីវិធានការដែលត្រូវអនុវត្ត បន្ទាប់ពីមាន "សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ" (ឯកសារ E138/1/10/1/5/7) (សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ស្ដីពីការត្រួតពិនិត្យលក្ខខណ្ឌនៃការដោះលែង អៀង ធីរិទ្ធ") និងសេចក្ដីសម្រេចរបស់ អ.ជ.ត.ក ស្ដីពីការត្រួតពិនិត្យ និងការបញ្ជាក់បំភ្លឺលើលក្ខខណ្ឌនៃការដោះលែង។

៣. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថាអនុស្សរណៈខាងលើ បានកែប្រែ និងផ្លាស់ប្ដូរវិធានការមួយចំនួនដែលកំពុងត្រូវបានដាក់លើជនជាប់ចោទ អៀង ធីរិទ្ធ។ អាស្រ័យហេតុនេះ អង្គជំនុំ-ជម្រះសាលាដំបូងយល់ឃើញថា ជាការចាំបាច់ដែលត្រូវធ្វើការបង្គាប់ដូចខាងក្រោមនេះ។

## ខ. សេចក្ដីបង្គាប់

**តាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ដូចតទៅ៖**

(1) ឱ្យជនជាប់ចោទ អៀង ធីរិទ្ធ ឬអាណាព្យាបាលទូទៅរបស់លោក ស្រី អៀង ធីរិទ្ធ ត្រូវជូនដំណឹងមកក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យ៉ាងតិច ០៧ ថ្ងៃ មុនពេលផ្លាស់ប្ដូរអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់លោក ស្រី អៀង ធីរិទ្ធ និងយ៉ាងតិច ០៧ ថ្ងៃមុនការស្នើសុំធ្វើដំណើរចាកចេញពីប្រទេសកម្ពុជា។ ក្នុងករណីដែលតម្រូវឱ្យបញ្ជូនជនជាប់ចោទ អៀង ធីរិទ្ធ ទៅទទួលការព្យាបាលបន្ទាន់នៅឯបរទេសត្រូវជូនដំណឹងមក

00939315



ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងឱ្យឆាប់រហ័សបំផុតតាមតែអាចធ្វើបានតាមការជាក់ស្ដែង និងឱ្យបានមុនពេលធ្វើការបញ្ជូននេះ។អង្គជំនុំជម្រះសាលាដំបូងនឹងបញ្ជាក់ពីការទទួលបាននូវការជូនដំណឹងពីការផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់ជនជាប់ចោទ ឬពីការអនុញ្ញាតឱ្យជនជាប់ចោទ អៀង ធីរិទ្ធ ធ្វើដំណើរចាកចេញ ឬបញ្ជូនចេញពីប្រទេសកម្ពុជាតាមការជាក់ស្ដែង។

(2) ឱ្យជនជាប់ចោទ អៀង ធីរិទ្ធ ឬ អាណាព្យាបាលទូទៅរបស់លោកស្រី អៀង ធីរិទ្ធ ផ្ដល់ការបញ្ជាក់ជារៀងរាល់ខែ នៅថ្ងៃចុងក្រោយនៃថ្ងៃធ្វើការក្នុងខែនីមួយៗ (ដែលចាប់ផ្ដើមនៅថ្ងៃ ពុធ ទី ៣១ ខែកក្កដា ឆ្នាំ ២០១៣) ជូនដល់អង្គជំនុំជម្រះសាលាដំបូងថាលោកស្រី អៀង ធីរិទ្ធ នៅតែរស់នៅលំនៅដ្ឋានដែលមានអាសយដ្ឋាននាពេលបច្ចុប្បន្នរបស់គាត់ និងរាយការណ៍អំពីការគម្រាមកំហែងណាមួយចំពោះសុវត្ថិភាពរបស់ អៀង ធីរិទ្ធ។ ប្រសិនបើធ្វើដូច្នេះបាននោះ អង្គជំនុំជម្រះសាលាដំបូងនឹងពុំតម្រូវឱ្យជនជាប់ចោទ អៀង ធីរិទ្ធ ឬនគរបាលយុត្តិធម៌ធ្វើការត្រួតពិនិត្យបញ្ហាសន្តិសុខបន្ថែមណាមួយឡើយ។

(3) អង្គជំនុំជម្រះសាលាដំបូងនឹងចេញដីកាបង្គាប់ដាច់ដោយឡែកមួយទាក់ទងនឹងការវាយតម្លៃឡើងវិញជាថ្មីទៀតទៅលើ អៀង ធីរិទ្ធ អំពីមុខងារសតិបញ្ញាស្មារតីរបស់គាត់នៅក្នុងខែ កញ្ញា ឆ្នាំ ២០១៣ និងការតែងតាំងអ្នកជំនាញមួយរូប នាពេលសមស្របខាងមុខ។

(4) ដីកាបង្គាប់នេះត្រូវជូនដំណឹងទៅសមត្ថកិច្ចកម្ពុជាដែលពាក់ព័ន្ធ។

ភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

និល ណុន